**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៦២ អនក្រ.បក/** ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០២

# អនុក្រឹត្យ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើសារពើពន្ធ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ / ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ ២៣ក្រ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ១៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតតែមប្រើសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់
- បានឃើញអនុក្រឹត្យ លេខ ៧៦អនក្រ ចុះថ្ងៃទី១១ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការកែលំអ និង បំពេញបន្ថែមអនុក្រឹត្យស្តីពីការប្រមូលពន្ធតែមប្រើ
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម លេខ នស/ រកម / ០១៩៦ /១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ នស/ រកត/០៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រាំទ្រ ឃុំ សង្កាត់
- យោងស្មារតីអង្គប្រជុំលើកទី១៤ របស់គណៈកម្មាធិការជាតិគ្រាំទ្រ ឃុំ សង្កាត់ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

មាត្រា១

ត្រូវបានកំណត់ថ្លៃជាវក្រដាសអនុត្រានុកូលដ្ឋាន គ្រប់ប្រភេទដូចខាងក្រោម :

**ក- ខេត្តរតនគីរី - មណ្ឌលគីរី - ស្ទឹងត្រែង ព្រះវិហារ និង ឧត្តរមានជ័យ :**

| | |
|---|---|
| - ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | កំណត់ ២០០រៀល ក្នុង ១ ទំព័រ |
| - សំបុត្រអាពាហ៍ពិពាហ៍ | កំណត់ ១០០រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | កំណត់ ១០០រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់កំណើត | កំណត់ ១០០រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់មរណភាព | កំណត់ ១០០រៀល ក្នុង ១ ទំព័រ |

- សេចក្តីចម្លង ឬ សម្រង់ សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ កំណត់ ១០០រៀល ក្នុង ១ ទំព័រ

**ខ- ខេត្ត ក្រុង ក្រៅពីខេត្តទាំង ០៥ ខាងលើ :**

- ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ កំណត់ ៤០០រៀល ក្នុង ១ ទំព័រ
- សំបុត្រអាពាហ៍ពិពាហ៍ កំណត់ ៤០០រៀល ក្នុង ១ ទំព័រ
- សំបុត្របញ្ជាក់ អាពាហ៍ពិពាហ៍ កំណត់ ៤០០រៀល ក្នុង ១ ទំព័រ
- សំបុត្របញ្ជាក់កំណើត កំណត់ ៤០០រៀល ក្នុង ១ ទំព័រ
- សំបុត្របញ្ជាក់មរណភាព កំណត់ ៤០០រៀល ក្នុង ១ ទំព័រ
- សេចក្តីចម្លង ឬ សម្រង់ សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ

មាត្រា ២

ថ្លៃតែមប្រិ៍សារពើពន្ធសំរាប់បិទលើក្រដាសអត្រានុកូលដ្ឋានត្រូវបានកំណត់ដូចខាងក្រោម :

-ពាក្យសុំរៀបអាពាហ៍ពិពាហ៍ កំណត់ ១០០០រៀល ក្នុង ១ ទំព័រ

- សេចក្តីចម្លង ឬ សម្រង់ សំបុត្រកំណើត កំណត់ ៣០០រៀល ក្នុង ១ ទំព័រ
- សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់ កំណើត កំណត់ ៣០០រៀល ក្នុង ១ ទំព័រ
- សេចក្តីចម្លង ឬ សម្រង់សំបុត្រ អាពាហ៍ពិពាហ៍ កំណត់ ១.៥០០រៀល ក្នុង ១ ទំព័រ
- សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់ អាពាហ៍ពិពាហ៍ កំណត់ ១.៥០០រៀល ក្នុង ១ ទំព័រ

-សេចក្តីចម្លង ឬ សម្រង់សំបុត្រមរណភាព កំណត់ ៤០០រៀល ក្នុង ១ ទំព័រ

-សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់មរណភាព កំណត់ ៤០០រៀល ក្នុង ១ ទំព័រ

មាត្រា ៣

ចំណូលដែលឃុំ សង្កាត់ ប្រមូលបានពីការលក់ក្រដាសអត្រានុកូដ្ឋានគ្រប់ប្រភេទ ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ត្រូវចាត់ជាចំណូលផ្ទាល់របស់ថវិកា ឃុំ សង្កាត់ ។

មាត្រា ៤

ក្រសួងមហាផ្ទៃមានភារកិច្ចបោះពុម្ពក្រដាសអត្រានុកូដ្ឋានគ្រប់ប្រភេទ សំរាប់ផ្គត់ផ្គង់ដល់អាជ្ញាធរដែលមានភារកិច្ចអនុវត្តការងារចុះបញ្ជីអត្រានុកូដ្ឋាន ។

មាត្រា ៥

ផ្អែកតាមស្មារតីនៃអនុក្រឹត្យនេះ ក្នុងករណីចាំបាច់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងបន្ថែមទៀត ។

មាត្រា ៦

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនិងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៨

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។